ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥ ០១៤ ៦៦៤ ធ.ស.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ប្រាក់បញ្ញើមានកាលកំណត់ នៅធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជ្រាបថា ដើម្បីផ្តល់ជម្រើសដល់ការវិនិយោគ និងបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងសន្ទនីយភាពសល់ទំនេរ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចដាក់ផ្ញើប្រាក់នៅធនាគារជាតិនៃកម្ពុជា ក្រោមរូបភាពជាប្រាក់បញ្ញើមានកាលកំណត់ ដោយទទួលបានការប្រាក់តាមអត្រាកំណត់របស់ធនាគារជាតិនៃកម្ពុជានាថ្ងៃដាក់ផ្ញើ និងតាមរយៈពេលនៃការដាក់ផ្ញើ។

ករណីមានតម្រូវការសន្ទនីយភាពចាំបាច់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចដកប្រាក់បញ្ញើនេះមុនកាលវសានបាន ដោយមិនទទួលបាននូវការប្រាក់ក្នុងអំឡុងពេលដាក់ផ្ញើ ព្រមទាំងត្រូវរងពិន័យចំនួន ៥០០.០០០រៀល (ប្រាំរយពាន់រៀល) ក្នុងមួយវិញ្ញាបនប័ត្រ។ ប្រាក់ពិន័យនេះនឹងត្រូវបានកាត់ជាស្វ័យប្រវត្តិពីគណនីចរន្តរបស់សាមីគ្រឹះស្ថាន។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤

**អគ្គនាយកបច្ចេកទេស**

ជា សិរី

**កន្លែងទទួល:**
- គ្រប់អគ្គនាយកដ្ឋាន "ដើម្បីជូនជ្រាប"
- នាយកដ្ឋានក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រប់សាខាធនាគារជាតិនៃកម្ពុជា

" ដើម្បីជ្រាបនិងសហការអនុវត្ត "